# ក្រុមការងារបច្ចេកទេសដែនជម្រកសត្វព្រៃកែវសីមាទទួលបានវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពស្តីពីការកំណត់និងបែងចែកតំបន់ការពារធម្មជាតិ

ដោយ លាក់ រតនា ( ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៩ )

ភ្នំពេញ ៖ សមាជិកក្រុមការងារបច្ចេកទេសកំណត់និងបែងចែកតំបន់ដែនជម្រកសត្វព្រៃកែវសីមា ទទួលបានវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពជាលើកដំបូងស្តីពី “ដំណើរការនិងនីតិវិធីកំណត់និងបែងចែក និងផែនការគ្រប់គ្រងដែនជម្រកសត្វព្រៃកែវសីមា” ក្រោយពីក្រុមនេះត្រូវបានបង្កើតឡើងកាលពីខែ សីហា ឆ្នាំកន្លងទៅ។

ដោយមានការគាំទ្រមូលនិធិពីទីភ្នាក់ងារអាម៉េរិកសម្រាប់កិច្ចអភិវឌ្ឍអន្តរជាតិ និងទីភ្នាក់ងារអភិវឌ្ឍនៃប្រទេសបារាំង អង្គការសមាគមអភិរក្សសត្វព្រៃបានសហការជាមួយក្រសួងបរិស្ថានរៀបចំវគ្គបណ្តុះបណ្តាលមួយដែលមានរយៈពេលពីរថ្ងៃចាប់ពីថ្ងៃទី ២៨ ដល់ ២៩ ខែ មីនា ក្នុងគោលបំណងដើម្បីផ្តល់ដល់អ្នកចូលរួមទាំងអស់នូវចំណេះដឹងអំពីគោលការណ៍ណែនាំនិងជំនាញបច្ចេកទេសមូលដ្ឋាន នីតិវិធី វិធីសាស្រ្ត និងឧបករណ៍សម្រាប់កំណត់និងបែងចែក និងគោលគំនិតសម្រាប់ធ្វើផែនការកំណត់ទីតាំងសម្រាប់តំបន់ការពារធម្មជាតិ និងចែករំលែកបទពិសោធន៍ទាក់ទងនឹងវិធីសាស្រ្តនៃការកំណត់និងបែងចែកតំបន់ដែនជម្រក និងសត្វព្រៃនៅតំបន់គូលេនព្រំទេព។

ឯកឧត្តម រ័ត្ន វីរៈ រដ្ឋលេខាធិការក្រសួងបរិស្ថាន បានថ្លែងនៅក្នុងសុន្ទរកថាបើកវគ្គបណ្តុះបណ្តាលនេះ ថា ការកំណត់និងបែងចែកតំបន់អភិរក្សមានសារៈសំខាន់ណាស់សម្រាប់អ្នកអភិរក្សទាំងអស់ និងចាំបាច់ត្រូវធ្វើឲ្យបានល្អ។ “ការចែករំលែកបទពិសោធន៍ថ្ងៃនេះ គឺជាមូលដ្ឋានមួយ ជាមេរៀនមួយ រួមចំណែកដល់ថ្នាក់ដឹកនាំក្រសួងបរិស្ថានទាំងមូល សម្រាប់ពិចារណាគិតគូរទៅតំបន់ផ្សេងទៀត។”

ឯកឧត្តម ញ៉ន សិទ្ធិ អភិបាលរងខេត្តមណ្ឌលគីរី បានមានប្រសាសន៍ថា បច្ចុប្បន្ន ដែនជម្រកសត្វព្រៃកែវសីមា កំពុងស្ថិតក្រោមការគំរាមកំហែងពីការកើនឡើងនៃការតាំងទីលំនៅរបស់ជនចំណាកស្រុក ការកាប់រុករានដីព្រៃធ្វើកសិកម្ម ការកាប់ឈើ បរបាញ់សត្វព្រៃ នេសាទត្រី ខុសច្បាប់ ។ល។

ឯកឧត្តម បានថ្លែងបន្តថា “ទាំងនេះជាសកម្មភាពធ្វើឲ្យប៉ះពាល់ដល់ជីវៈចម្រុះ ធនធានធម្មជាតិ និងការប្រកបរបររស់នៅរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលរស់នៅពឹងផ្អែកលើធនធានធម្មជាតិនៅមូលដ្ឋាន ពិសេស គម្រោងរេដបូកនៃដែនជម្រកសត្វព្រៃកែវសីមា។ ដោយហេតុថា ជនជាតិដើមភាគតិចភាគច្រើនរស់នៅនិងប្រកបរបរកសិកម្មប្រពៃណីនៅក្នុងដែនជម្រកសត្វព្រៃកែវសីមា ការពិគ្រោះយោបល់ជាមួយពួកគាត់អំពីការកំណត់និងបែងចែកតំបន់គ្រប់គ្រងគឺជាការចាំបាច់ ដើម្បីធានាថា ពួកគាត់ទទួលបានសិទ្ធិប្រើប្រាស់ដីស្របតាមច្បាប់ភូមិបាល និងចូលរួមការពារដែនជម្រកសត្វព្រៃប្រកបដោយប្រសិទ្ធិភាព។”

បណ្ឌិត កែន សេរីរដ្ឋា នាយកអង្គការសមាគមអភិរក្សសត្វព្រៃ បានស្នើដល់អ្នកចូលរួមវគ្គបណ្តុះបណ្តាលទាំងអស់ ផ្តោតការយកចិត្តទុកដាក់លើនីតិវិធីនិងដំណើរការនៃការប្រមូលធាតុចូល និងប្រើប្រាស់ធាតុចូលទាំងនោះជាមូលដ្ឋានសម្រាប់រៀបចំសេចក្តីព្រៀងស្តីពីការកំណត់និងបែងចែកដែនជម្រកសត្វព្រៃកែវសីមា។

លោក បានមានប្រសាសន៍បន្ថែមថា អង្គការសមាគមអភិរក្សសត្វព្រៃកំពុងប្រើនូវបច្ចេកវិទ្យាកុំព្យូទ័រថ្មីមួយដែលជួយសម្រួលដល់ដំណើរការវិភាគលក្ខណៈវិនិច្ឆ័យចម្រុះ ដោយប្រើប្រាស់នូវទិន្នន័យទីតាំងដើម្បីគាំទ្រដល់ការសម្រេចចិត្តក្នុងការកំណត់និងបែងចែកតំបន់ ឆ្លើយតបទៅនឹងទិសដៅមួយចំនួនដូចជា ការសម្រេចគោលដៅនានាដែលបានកំណត់ក្នុងគោលនយោបាយជាតិ សម្រេចបានការងារអភិរក្សជីវៈចម្រុះ គាំទ្រដល់ជីវភាពរស់នៅរបស់សហគមន៍ ការពារកេរ្តិ៍ដំណែលវប្បធម៌ និងការគ្រប់គ្រងធនធានធម្មជាតិ។ ដំណើរការនេះ នឹងរួមបញ្ចូលនូវធាតុចូលរបស់សហគមន៍តាមរយៈការពិគ្រោះយោបល់ និងការកំណត់ទីតាំងដោយមានការចូលរួម និងរួមបញ្ចូលមតិយោបល់របស់សហគមន៍មូលដ្ឋាន មន្ទីរ នាយកដ្ឋានពាក់ព័ន្ធ និងភាគីពាក់ព័ន្ធដទៃទៀត។

លោក បណ្ឌិត សេរីវឌ្ឍា បានមានប្រសាសន៍ថា “នេះគឺជាការពិគ្រោះយោបល់មួយដើម្បីប្រមូលធាតុចូលនៅថ្នាក់ក្រោមជាតិ។ បន្ទាប់មក នឹងមានការរៀបចំកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីប្រមូលធាតុចូលបន្ថែមយកមកបំពេញសេចក្តីព្រាង នេះ មុននឹងដាក់បញ្ជូនទៅក្រសួងបរិស្ថានដើម្បីពិនិត្យ។”

វគ្គបណ្តុះបណ្តាលនេះ មានអ្នកចូលរួមចំនួន ៤៣នាក់ ដែលរួមមានសមាសភាពដូចជា មេឃុំ មន្ត្រីថ្នាក់ស្រុកនិងខេត្តមកពីខេត្តមណ្ឌលគីរី និងខេត្តក្រចេះ បុគ្គលិកអង្គការសមាគមអភិរក្សសត្វព្រៃ និងមន្ត្រីបច្ចេកទេសរបស់ក្រសួងបរិស្ថានជាច្រើនរូបទៀត៕